| |
|---|
| តុលាការខេត្ត<br>សៀមរាប-ឧត្តរមានជ័យ<br>សាលក្រម<br>លេខ ៧៦ ខ ចុះថ្ងៃទី ១៤<br>ខែ មិថុនា ឆ្នាំ ២០០៦<br>សំណុំរឿងរដ្ឋប្បវេណី<br>លេខ ១៨៧ ចុះថ្ងៃទី ២៦<br>ខែ ឧសភា ឆ្នាំ ២០០៦ |

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

### នាមប្រជារាស្ត្រខ្មែរ

### តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នាថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៦ ដោយមានសមាសភាព :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ប្រធានតុលាការខេត្ត

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្ត

សាលក្រមនេះចូលជាស្ថាពរចាប់ពីថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៦
ដោយគ្មានភាគីណាចូលមកប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។
សៀមរាប,ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៦
ក្រឡាបញ្ជី
ហត្ថលេខា និង ត្រា
[redacted]

ដើម្បីជំនុំជំរះសំណុំរឿងក្តីរដ្ឋប្បវេណីលេខ ១៨៧ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ ដែលមានកម្មវត្ថុ **ប្តឹងសុំលែងលះប្តី . ប្តឹងសុំសិទ្ធិគ្រប់គ្រងកូន** ។

រវាងដើមចោទឈ្មោះ **អ គពស** ភេទស្រី អាយុ ២២ឆ្នាំ មុខរបរលក់បន្លែ ទីលំនៅៗភូមិដកពោធិ៍ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ **អ សរ** (រ) ម្តាយឈ្មោះ **អ ល** (រ) ប្តីឈ្មោះ **យ មឧ** មានកូន ០១នាក់ ។

និង ចុងចម្លើយឈ្មោះ **យ មឧ** ភេទប្រុស អាយុ ៣១ឆ្នាំ មុខរបរគ្មាន ទីលំនៅៗ ភូមិដកពោធិ៍ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ **យ ឧ** (រ) ម្តាយឈ្មោះ **ម អ** (រ) ប្រពន្ធឈ្មោះ **អ គពស** មានកូន ០១នាក់ ។

### ដំណើររឿងមានដូចតទៅ :

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៦ ដើមចោទឈ្មោះ **អ គពស** បានប្តឹងសុំលែងលះប្តីឈ្មោះ **យ មឧ** ដោយមូលហេតុការរស់នៅមិនចុះសំរុងនឹងគ្នា ហើយប្តីខ្លួនធ្លាប់ចុះចោលខ្លួនជាច្រើនលើកមក ហើយធ្វើអោយខ្លួនមិនអាចស៊ូទ្រាំរស់នៅជាប្តីប្រពន្ធតទៅទៀតបាន ។ ទ្រព្យសម្បត្តិរួមគ្មានអ្វីទេ ។ បំណុលរួមមានជំពាក់គេលេងតុងទីន ៦២៥០ដុល្លា "ប្រាំមួយពាន់ពីររយហាសិបដុល្លា" និង គេជំពាក់ថ្លៃលេងតុងទីនដែរចំនួន ២៧៥០ដុល្លា " ពីរពាន់ប្រាំពីររយហាសិបដុល្លា " ។

## នារពលសទនាគារ

ដើមចោទឈ្មោះ អ គពស បានឆ្លើយថា ខ្លួនប្តឹងសុំលែងលះប្តីឈ្មោះ យ បឧ ដោយមូលហេតុការរស់នៅមិនចុះសំរុងគ្នា ប្តីខ្លួនធ្លាប់ចុះចោលខ្លួនជាច្រើនលើកច្រើនសារ ពេលខ្លួនកូនខ្ចីមិនជួយមើលខ្លួនទេ ចុះចោលខ្លួន លេងល្បែងមិនជួយរកស៊ីខ្លួនទេ ជាហេតុធ្វើអោយខ្លួនមិនអាចស៊ូទ្រាំរស់នៅជាប្តីប្រពន្ធតទៅទៀតបានទេ ។ ខ្លួនអស់មនោសញ្ចេតនាពីប្តីហើយ ។

តាំងពីរៀបការមកមានកូនស្រីម្នាក់ឈ្មោះ យ គឧរស អាយុ ១៤ខែ ខ្លួនសុំសិទ្ធិគ្រប់គ្រង ។

ចំពោះអាហារកិច្ចចិញ្ចឹមកូន ខ្លួនមិនទាមទារឡើយ ខ្លួនធានាចិញ្ចឹមកូនតែម្នាក់ឯង ។

ទ្រព្យសម្បត្តិរួមគ្មានអ្វីពាក់ព័ន្ធនឹងគ្នាទេ ។

បំណុលរួមមានជំពាក់ថ្លៃលេងតុងទីនឈ្មោះ :

១-អ៊ុំ រ៉ាត់ ចំនួន ១.០០០ដុល្លា " មួយពាន់ដុល្លា "
២-ចាន់ណា ចំនួន ៦០០ដុល្លា " ប្រាំមួយរយដុល្លា "
៣-នាង ហ្វូច ចំនួន ៨០០ដុល្លា " ប្រាំបីរយដុល្លា "
៤-រ៉េន ចំនួន ៦០០ដុល្លា " ប្រាំមួយរយដុល្លា "
៥-អ៊ុំ នាង ចំនួន ៦០០ដុល្លា " ប្រាំមួយរយដុល្លា "
៦-អ៊ុំ រួន ចំនួន ១០០ដុល្លា " មួយរយដុល្លា "
៧-យន់ ចំនួន ២០០ដុល្លា " ពីររយដុល្លា "
៨-អិន់ ចំនួន ៤០០ដុល្លា " បួនរយដុល្លា "
៩-តៀយ ចំនួន ៣០០ដុល្លា " បីរយដុល្លា "
១០-ហឿន ចំនួន ១.២០០ដុល្លា " មួយពាន់ពីរយដុល្លា "

សរុបទាំងអស់ ៦២៥០ដុល្លា "ប្រាំមួយពាន់ពីររយហាសិបដុល្លាគត់" ខ្លួនធានាចេញសងទៅម្ចាស់បំណុលតែម្នាក់ឯង ដោយមិនអោយចុងចម្លើយឈ្មោះ យ បឧ ជួយចេញសងឡើយ រីឯបំណុលដែលគេជំពាក់ខ្លួនវិញមានឈ្មោះ :

១-ម៉ាក់ ស្រីនាង ចំនួន ១.២០០ដុល្លា " មួយពាន់ពីររយដុល្លា "
២-សេង ចំនួន ១.០០០ដុល្លា " មួយពាន់ដុល្លា "
៣-រ័ត្ន ចំនួន ១៥០ដុល្លា " មួយរយហាសិបដុល្លា "
៤-រឿម ចំនួន ៤០០ដុល្លា " បួនរយដុល្លា "

សរុបចំនួន ២៧៥០ដុល្លា " ពីរពាន់ប្រាំពីររយហាសិបដុល្លា " ខ្លួនសុំទារប្រាក់ជំពាក់នេះ ដើម្បីទុកទូទាត់សងបំណុលគេ នៅជំពាក់គេប៉ុន្មានទៀតជាបន្ទុករបស់ខ្លួនជាអ្នកសង មិនអោយចុងចម្លើយ យ បឧ សងឡើយ ។

ចុងចម្លើយឈ្មោះ យ បឧ បានឆ្លើយថា ខ្លួនមិនព្រមលែងលះដើមចោទ ដោយមូលហេតុខ្លួននៅតែអាណិតស្រឡាញ់ប្រពន្ធ និង កូន ទោះបីការរស់នៅមិនចុះសំរុងនឹងគ្នាក៏ដោយ ក៏ខ្លួនមិនព្រមលែងលះដែរ ។ ថាកន្លងមកខ្លួនពិតជាបានចុះចោលប្រពន្ធមែន ។

កូនស្រីម្នាក់ឈ្មោះ យ គឧរស អាយុ ១៤ខែ ខ្លួនសុខចិត្តប្រគល់អោយដើមចោទឈ្មោះ អ គពស គ្រប់គ្រងចុះ ។

ចំពោះអាហារកិច្ចចិញ្ចឹមកូន ខ្លួនគ្មានលទ្ធភាពចិញ្ចឹមកូនទេពេលនេះ តែពេលក្រោយពេលណាខ្លួនមានលទ្ធភាពខ្លួននឹងជួយចិញ្ចឹមកូនតាមលទ្ធភាព ។

ទ្រព្យសម្បត្តិរួមគ្មានអ្វីពាក់ព័ន្ធនឹងគ្នាទេ ។

បំណុលរួមមានជំពាក់ថ្លៃលេងតុងទីនឈ្មោះ :

១-អ៊ុំ វ៉ាត់ ចំនួន ១.០០០ដុល្លា "មួយពាន់ដុល្លា"
២-ចាន់ណា ចំនួន ៦០០ដុល្លា "ប្រាំមួយរយដុល្លា"
៣-នាង ហួច ចំនួន ៨០០ដុល្លា "ប្រាំបីរយដុល្លា"
៤-រ៉េន ចំនួន ៦០០ដុល្លា "ប្រាំមួយរយដុល្លា"
៥-អ៊ុំ នាង ចំនួន ៦០០ដុល្លា "ប្រាំមួយរយដុល្លា"
៦-អ៊ុំ រួន ចំនួន ១០០ដុល្លា "មួយរយដុល្លា"
៧-យន់ ចំនួន ២០០ដុល្លា "ពីររយដុល្លា"
៨-អិន់ ចំនួន ៤០០ដុល្លា "បួនរយដុល្លា"
៩-តៀយ ចំនួន ៣០០ដុល្លា "បីរយដុល្លា"
១០-ហៀន ចំនួន ១.២០០ដុល្លា "មួយពាន់ពីររយដុល្លា"

សរុបទាំងអស់ ៦២៥០ដុល្លា "ប្រាំមួយពាន់ពីររយហាសិបដុល្លាគត់" ខ្លួនប្រគល់អោយដើមចោទសងទៅម្ចាស់បំណុលតែម្នាក់ឯងចុះ ។

រីឯបំណុលដែលគេជំពាក់ខ្លួនវិញមានឈ្មោះ :

១-ម៉ាត់ [redacted] ចំនួន ១.២០០ដុល្លា "មួយពាន់ពីររយដុល្លា"
២-សេខ ចំនួន ១.០០០ដុល្លា "មួយពាន់ដុល្លា"
៣-រ័ត្ន ចំនួន ១៥០ដុល្លា "មួយរយហាសិបដុល្លា"
៤-រៀម ចំនួន ៤០០ដុល្លា "បួនរយដុល្លា"

សរុបចំនួន ២៧៥០ដុល្លា "ពីរពាន់ប្រាំពីររយហាសិបដុល្លា" ខ្លួនទុកអោយដើមចោទទារយកទៅសងបំណុលគេចុះ ខ្លួនមិនទាមទារយកទេ ។

## តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា

រឿងក្ដីនេះជារឿងរដ្ឋប្បវេណី ដែលជាប្រភេទរឿងអាពាហ៍ពិពាហ៍ និង គ្រួសារ ដោយគោលបំណងអាពាហ៍ពិពាហ៍លែងបានសំរេច ហើយមានសភាពធ្ងន់ធ្ងរ គូភាគីទាំងពីរពុំអាចរស់នៅជាមួយគ្នាតទៅទៀតបាន ព្រោះដើមចោទ និង ចុងចម្លើយអស់មនោសញ្ចេតនាពីគ្នាហើយ ។ ទោះបីមានការលែងលះគ្នាក៏ដោយ ភាគីទាំងពីរមិនទុកគ្នាជាសត្រូវ ហើយឪពុកម្ដាយត្រូវមានកាតព្វកិច្ច អប់រំ ចិញ្ចឹមកូនតាមច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។ ហេតុនេះសូមតុលាការពិចារណាសំរេចតាមច្បាប់ចុះ ។

-បានស្ដាប់ចម្លើយដើមចោទឆ្លើយអោយការណ៍ និង ប្ដឹងសុំ

-បានស្ដាប់ចម្លើយចុងចម្លើយឆ្លើយដោះសារ

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យត្រឹមត្រូវហើយ

**តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ**

**យល់ឃើញថា**

-ទទួលពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៦ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-គូស្វាមីភរិយានេះបានគ្នាជាប្តីប្រពន្ធមានចំណងអាពាហ៍ពិពាហ៍តាមច្បាប់ ។

-ដើមចោទប្តឹងសុំលែងលះចុងចម្លើយ ហើយចុងចម្លើយព្រមព្រៀងនោះ តុលាការនឹងពិចារណាដល់បញ្ហាតាមច្បាប់ ។

-ដើមចោទប្តឹងសុំសិទ្ធិគ្រប់គ្រងកូនស្រីម្នាក់ឈ្មោះ យ គធរស ហើយចុងចម្លើយក៏បានព្រមព្រៀងដែរនោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-ដើមចោទមិនប្តឹងសុំប្រាក់អាហារកិច្ចចិញ្ចឹមកូនពីចុងចម្លើយទេនោះ តុលាការមិនពិចារណាដល់បញ្ហានេះឡើយ ។

-ទ្រព្យសម្បត្តិរួមគ្មានអ្វីពាក់ព័ន្ធទេ តុលាការមិនពិចារណាដល់បញ្ហានេះឡើយ ។

-បំណុលរួមមានជំពាក់ថ្លៃលេងតុងទីនឈ្មោះ :

១-អ៊ុំ រ៉ាត់ ចំនួន ១០០០ដុល្លា " មួយពាន់ដុល្លា "
២-ចាន់ណា ចំនួន ៦០០ដុល្លា " ប្រាំមួយរយដុល្លា "
៣-នាង ហួច ចំនួន ៨០០ដុល្លា " ប្រាំបីរយដុល្លា "
៤-រ៉េន ចំនួន ៦០០ដុល្លា " ប្រាំមួយរយដុល្លា "
៥-អ៊ុំ នាង ចំនួន ៦០០ដុល្លា " ប្រាំមួយរយដុល្លា "
៦-អ៊ុំ រួន ចំនួន ១០០ដុល្លា " មួយរយដុល្លា "
៧-យន់ ចំនួន ២០០ដុល្លា " ពីររយដុល្លា "
៨-អិន់ ចំនួន ៤០០ដុល្លា " បួនរយដុល្លា "
៩-តៀយ ចំនួន ៣០០ដុល្លា " បីរយដុល្លា "
១០-ហៀន ចំនួន ១២០០ដុល្លា " មួយពាន់ពីរយដុល្លា "

សរុបទាំងអស់ ៦២៥០ដុល្លា " ប្រាំមួយពាន់ពីរយហាសិបដុល្លាគត់ " ដើមចោទទទួលរ៉ាប់សងទៅម្ចាស់បំណុលតែម្នាក់ឯង ហើយចុងចម្លើយយល់ព្រមដែរនោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។ រីឯបំណុលដែលគេជំពាក់មានឈ្មោះ :

១-ម៉ាក់ ស្រីនាង ចំនួន ១២០០ដុល្លា " មួយពាន់ពីររយដុល្លា "
២-សេខ ចំនួន ១០០០ដុល្លា " មួយពាន់ដុល្លា "
៣-រ័ត្ន ចំនួន ១៥០ដុល្លា " មួយរយហាសិបដុល្លា "
៤-រៀម ចំនួន ៤០០ដុល្លា " បួនរយដុល្លា "

សរុបចំនួន ២៧៥០ដុល្លា " ពីរពាន់ប្រាំពីរយហាសិបដុល្លា " ដើមចោទសុំទារយកទៅសងបំណុលគេ ហើយចុងចម្លើយយល់ព្រមដែរនោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-គោលដៅនៃអាពាហ៍ពិពាហ៍ពុំអាចសំរេចបានឡើយ ដោយដើមចោទអស់មនោសញ្ចេតនាពីចុងចម្លើយ ។

## ហេតុដូច្នេះទើបវិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-សំរេចអោយអ្នកស្រី អ គពស និង លោក ឃ បឧ លែងលះគ្នាចាប់ពីថ្ងៃនេះតទៅ ។ ដាក់កំហុសប្តី ។

៣-សំរេចអោយអ្នកស្រី អ គពស ស្ថិតនៅភាពជាមេម៉ាយចំនួន ៣០០ថ្ងៃ ចាប់ពីពេលនេះតទៅ ។

៤-កូនស្រីម្នាក់ឈ្មោះ ឃ គធរស អាយុ ១៤ខែ ត្រូវប្រគល់អោយទៅអ្នកស្រី អ គពស គ្រប់គ្រងតាមការព្រមព្រៀងរបស់គូភាគី ។ ហើយឈ្មោះ ឃ បឧ ត្រូវជួយចិញ្ចឹមកូនតាមលទ្ធភាពដែលខ្លួនមាន ។ មាតាបិតាត្រូវមានសិទ្ធិ និង ករណីកិច្ចអប់រំ ថែរក្សា ចិញ្ចឹមកូន តាមមាត្រា ៧៤ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

៥-ទុកសិទ្ធិអោយចុងចម្លើយទៅសួរសុខទុក្ខដល់កូនបាន ។

៦-បំណុលរួមមាន :

ក-ជំពាក់ថ្លៃលេងតុងទីនឈ្មោះ :

| | | |
|---|---|---|
| ១-អ៊ី រ៉ាត់ | ចំនួន ១.០០០ដុល្លា | "មួយពាន់ដុល្លា" |
| ២-ចាន់ណា | ចំនួន ៦០០ដុល្លា | "ប្រាំមួយរយដុល្លា" |
| ៣-នាង ហួច | ចំនួន ៨០០ដុល្លា | "ប្រាំបីរយដុល្លា" |
| ៤-អេន | ចំនួន ៦០០ដុល្លា | "ប្រាំមួយរយដុល្លា" |
| ៥-អ៊ី នាង | ចំនួន ៦០០ដុល្លា | "ប្រាំមួយរយដុល្លា" |
| ៦-អ៊ី រួន | ចំនួន ១០០ដុល្លា | "មួយរយដុល្លា" |
| ៧-យន់ | ចំនួន ២០០ដុល្លា | "ពីររយដុល្លា" |
| ៨-អិន់ | ចំនួន ៤០០ដុល្លា | "បួនរយដុល្លា" |
| ៩-គៀយ | ចំនួន ៣០០ដុល្លា | "បីរយដុល្លា" |
| ១០-ហៀន | ចំនួន ១.២០០ដុល្លា | "មួយពាន់ពីរយដុល្លា" |

សរុបទាំងអស់ ៦២៥០ដុល្លា "ប្រាំមួយពាន់ពីររយហាសិបដុល្លា" គឺជាបន្ទុករបស់ដើមចោទឈ្មោះ អ គពស តាមការព្រមព្រៀងរបស់គូរភាគី ។

ខ-បំណុលដែលគេជំពាក់វិញមាន :

| | | |
|---|---|---|
| ១-ម៉ាត់ ស្រីនាង | ចំនួន ១.២០០ដុល្លា | "មួយពាន់ពីររយដុល្លា" |
| ២-សេខ | ចំនួន ១.០០០ដុល្លា | "មួយពាន់ដុល្លា" |
| ៣-វន្ត | ចំនួន ១៥០ដុល្លា | "មួយរយហាសិបដុល្លា" |
| ៤-រៀម | ចំនួន ៤០០ដុល្លា | "បួនរយដុល្លា" |

សរុបទាំងអស់ ២៧៥០ដុល្លា "ពីរពាន់ប្រាំពីររយហាសិបដុល្លា" ត្រូវប្រគល់អោយទៅដើមចោទឈ្មោះ អ គពស តាមការព្រមព្រៀងរបស់គូភាគី ។

៧-សំរេចអោយដើមចោទបង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វ៊ីង ១.៨០០៛០០ រង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់ ២០០៛០០ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛០០ បូករួម ៧.០០០៛០០ ។ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០៛០០ ដែលដើមចោទបានបង់ទុករួចហើយ កាលបើហូសឧទ្ធរណ៍ត្រូវបង្គាប់អោយចុងចម្លើយសងប្រាក់ ៧.០០០៛០០ នេះទៅដើមចោទវិញ ។

៨-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវឧទ្ធរណ៍កំណត់ ០២ខែចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

**ក្រឡាបញ្ជីសវនាការ** [redacted]

**ចៅក្រមជំនុំជំរះ** [redacted]